**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គនាយកដ្ឋានកសិកម្ម**

លេខ...១៤៥៧.......អ.ន.ក

រាជធានីភ្នំពេញ, ថ្ងៃទី..២៥..ខែ...សីហា...ឆ្នាំ ២០១៧

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ** : របាយការណ៍ប្រចាំខែសីហាស្តីពីល្បឿនការងារបង្កបង្កើនផលកសិកម្មរដូវវស្សាឆ្នាំ២០១៧ "គិតត្រឹមថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០១៧" ។

**ជូនភ្ជាប់** : របាយការណ៍លំអិតប្រចាំខែសីហាស្តីពីល្បឿនការងារបង្កបង្កើនផលកសិកម្មរដូវវស្សាឆ្នាំ២០១៧ "គិតត្រឹមថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៧" ចំនួន១ច្បាប់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន**ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ល្បឿនការងារបង្កបង្កើនផលកសិកម្មរដូវវស្សា ឆ្នាំ២០១៧ " គិតត្រឹមថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៧ " សម្រេចបាន:

១. ការងារបង្កបង្កើនផលកសិកម្មរដូវវស្សា ឆ្នាំ២០១៧ :

ក.ដំណាំស្រូវ : ស្ទូងនិងព្រោះអនុវត្តបានចំនួន ២.៤៥១.០០០ ហ.តស្មើនឹង៩៨,១៧% នៃផែនការចំនួន ២.៤៩៦.៧៩០ ហ.ត ល្បឿនជាងឆ្នាំមុន ៩៩.៤៦០ ហ.ត

ខ.ដំណាំរួមផ្សំ : អនុវត្តបាន ៧៥៤.៨២៩ ហ.ត យឺតជាងឆ្នាំមុន ៤៦.៧៦០ ហ.ត

គ.ដំណាំឧស្សាហកម្ម : អនុវត្តបាន ៨៦.៣៩៣ ហ.ត ល្បឿនជាងឆ្នាំមុន ៥០៩ ហ.ត

២. ការងារប្រមូលផលស្រូវស្រាលដើមរដូវវស្សា ឆ្នាំ២០១៧ :

មកដល់ពេលនេះ កសិករបានប្រមូលផលស្រូវស្រាលដើមរដូវវស្សាលើផ្ទៃដី ២៣១.៥៥៦ ហ.ត ទទួលបានទិន្នផលមធ្យម ៤,០៩៨ តោន/ហ.ត និងបរិមាណផលសរុប ៩៤៨.៩២០ តោន។

អាស្រ័យហេតុដូចបានគោរពជូនខាងលើសូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបជាសេចក្តីរាយការណ៍ដោយក្តីអនុគ្រោះ។ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក**
**នៃអគ្គនាយកដ្ឋានកសិកម្ម**

**បណ្ឌិត ហ៊ាន វណ្ណហាន**

<u>ចំលងជូន</u> ៖

- ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុកអគ្គនាយកដ្ឋានកសិកម្ម
- ឯកឧត្តម លោកជំទាវ អនុរដ្ឋលេខាធិការទទួលបន្ទុកអគ្គនាយកដ្ឋានកសិកម្ម
- ឯកឧត្តមអគ្គលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
  " ដើម្បីគោរពជូនជ្រាប "
- នាយកដ្ឋានកិច្ចការរដ្ឋបាល
- នាយកដ្ឋានផែនការ និងស្ថិតិ
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋានលេខ: ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ: (០២៣) ៨៨៣ ៤២៧. ទូរសារលេខ:(០២៣) ៨៨៣ ៤២៧
Address # 54B/49F, Street 395-656, Sangkat Toeuk Laak 3, Khan Tuol Kok, Phnom Penh, Cambodia, Phone: (023) 883 427, Fax: (023) 883 427